PTI0061

# សម្ភាសន៍ជាមួយឈ្មោះ អ៊ី ឆុន ភេទប្រុស អាយុ៥៧ឆ្នាំ

រស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់

មុខងារសម័យខ្មែរក្រហមៈ ទាហានខ្មែរក្រហម

មុខងារបច្ចុប្បន្នៈ ធ្វើចំការ

សម្ភាសន៍ដោយៈ ឡុង ដានី

សម្ភាសន៍ថ្ងៃទី២០ ខែ ឧសភា ឆ្នាំ២០១១

សរុបទំព័រៈ ២៧

០១:០០:៣៤

ដានីៈ អញ្ជើញជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអីដែរ?

ឆុនៈ ខ្ញុំឈ្មោះ អ៊ី ឆុន ។

ដានីៈ ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ឆុនៈ អាយុ៥៧ឆ្នាំ ។

ដានីៈ សព្វថ្ងៃពូនៅភូមិអីដែរ?

ឆុនៈ ភូមិនៅពេលថ្ងៃនេះ?

ដានីៈ បាទ! ភូមិយើងរស់នៅសព្វថ្ងៃនេះ?

ឆុនៈ ភូមិស្ទឹងថ្មី ។

ដានីៈ ឃុំអី?

ឆុនៈ ឃុំប្រម៉ោយ ។

ដានីៈ ស្រុក?

ឆុនៈ វាលវែង ។

ដានីៈ ខេត្ត?

ឆុនៈ ពោធិ៍សាត់ ។

ដានីៈ ប្រពន្ធពូគាត់ឈ្មោះអីដែរ?

ឆុនៈ ឈ្មោះ ជុំ ឃីប ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

ឆុនៈ មិនដឹងប៉ុន្មានទេ ដឹងតែកំណើតឆ្នាំ១៩៦៧ ។

ដានីៈ ពូមានកូនចៅប៉ុន្មានដែរ?

នុនៈ មានកូន២នាក់ ។

ដានីៈ ហើយស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

នុនៈ ប្រុសទាំង២នាក់ ។

ដានីៈ ពូសព្វថ្ងៃប្រកបមុខរបរធ្វើអីដែរ?

នុនៈ ធ្វើចំការ ព្រោះអត់មានអីធ្វើផង ។

ដានីៈ ធ្វើចំការអត់មានស្រែទេអញ្ចឹង?

នុនៈ អត់មានទេ ស្រែមានតែបន្តិចហ្នឹង ។

ដានីៈ ហើយពូធ្វើចំការច្រើន?

នុនៈ បន្តិចដែរហ្នឹង ។

ដានីៈ មានប៉ុន្មានហាត់ដែរ?

នុនៈ មាន៣ហាត់ហ្នឹង ។

ដានីៈ ពូ ស្រុកកំណើតរបស់ពូនៅភូមិឃុំស្រុកអីដែរ?

នុនៈ ស្រុកកំណើតនៅកំពត ។

ដានីៈ នៅភូមិអីគេ?

នុនៈ នៅភូមិព្រៃក្រាំង ។

ដានីៈ ឃុំអី?

នុនៈ ឃុំមានរិទ្ធ ។

ដានីៈ ស្រុក?

នុនៈ ស្រុកដងទង់ ខេត្តកំពត ។

ដានីៈ ឪពុកពូគាត់ឈ្មោះអីដែរ?

នុនៈ ឪពុកខ្ញុំស្លាប់ហើយ ។

ដានីៈ ប៉ុន្តែគាត់ឈ្មោះអីដែរ?

នុនៈ ឈ្មោះ អ៊ុ ឆេង ។

ដានីៈ គាត់ស្លាប់តាំងពីពេលណា?

នុនៈ គាត់ស្លាប់ពីបីឆ្នាំហើយ ។

ដានីៈ ទើបតែស្លាប់ឥលូវដែរ?

នុនៈ បាទ!

ដានី: ចុះម្តាយពូ?

ឆុនៈ ម្តាយក៏ស្លាប់ ទើបតែស្លាប់មួយឆ្នាំ ។

ដានី: គាត់ឈ្មោះអីដែរ?

ឆុនៈ សុខ សឹង ។

ដានី: ពូមានបងប្អូនទាំងអស់ប៉ុន្មាននាក់?

ឆុនៈ មាន៧នាក់ ។

ដានី: ស្រីប៉ុន្មានហើយប្រុសប៉ុន្មាន?

ឆុនៈ ស្រី៤នាក់ ហើយប្រុស៣នាក់ ។

ដានី: ហើយពូកូនទីប៉ុន្មាន?

ឆុនៈ ខ្ញុំកូនទី៤ ។

ដានី: ចុះពូកាលពីក្មេងៗបានរៀនសូត្រដល់ណាដែរ?

ឆុនៈ ខ្ញុំរៀនថ្នាក់ទី៩ចាស់ កាលពីជំនាន់សម្តេច ។

ដានី: ពូរៀននៅសាលាណាដែរ?

ឆុនៈ រៀននៅសាលាវត្តអង្គរមាស ។

ដានី: អង្គរមាសនៅណាដែរទៅ?

ឆុនៈ ឥលូវគេដាក់ក្រាំងលាវ ។

ដានី: ក្រាំងលាវហ្នឹងនៅក្នុងភូមិឃុំអីដែរ?

ឆុនៈ ឃុំមានរិទ្ធ ។

ដានី: ហើយពូឈប់រៀននៅឆ្នាំណាទៅ?

ឆុនៈ និយាយពីរឿងឈប់រៀនមិនដឹងជាឆ្នាំណាទេ ដឹងតែរៀនបាន៤ឆ្នាំ មិនដឹងឆ្នាំប៉ុន្មានទេ ។

ដានី: មុនរដ្ឋប្រហារ ឬក៏រដ្ឋប្រហារ?

ឆុនៈ ឈប់មុន ។

ដានី: យូឬក៏ឆាប់ដែរ?

ឆុនៈ ជិតរដ្ឋប្រហារហើយបានឈប់ កាលហ្នឹងរៀនបាន៤ឆ្នាំបានឈប់ កាលហ្នឹងខ្ញុំចូលរៀនដូចជាអាយុប៉ុន្មានទេ មិនដល់១២ទេដឹង ។

ដានី: ហើយពូឈប់រៀនហើយ ពូធ្វើអីទៀតទៅ?

ឆុនៈ អត់ធ្វើអីផង នៅជាមួយឪពុកម្តាយ ដល់ពេលក្រោយរដ្ឋប្រហារមកធ្វើគ្រូបង្រៀនក្មេងៗនៅភូមិណា៎ ។

ដានី: នៅជាមួយឪពុកម្ដាយធ្វើស្រែធ្វើចំការទៅ?

នុន: ធ្វើតែស្រែទេ អត់មានធ្វើចំការទេ។

ដានី: ដល់ពេលរដ្ឋប្រហារហើយ?

នុន: រដ្ឋប្រហារហើយក៏អត់ទាន់ចេញដែរ គេឲ្យនៅបង្រៀនក្មេងតាមភូមិ កាលហ្នឹងគេមិនបិទសាលាបិទអី ហើយគេបង្រៀនតាមភូមិ។

ដានី: អញ្ចឹងបង្រៀនក្មេងនៅតាមភូមិអញ្ចឹង?

នុន: បាទ!

ដានី: តាមភូមិណា?

នុន: ភូមិដែលខ្ញុំនៅហ្នឹង។

ដានី: ភូមិកំណើតហ្នឹង?

នុន: បាទ!

ដានី: រៀនបានរយៈពេលប៉ុន្មានឆ្នាំ?

នុន: រៀនបាន២ឆ្នាំក៏ឈប់ទៅ។

ដានី: រៀនពីអីទៅ បង្រៀនក្មេងហ្នឹង?

នុន: រៀនតាមសៀវភៅពីដើម តែសៀវភៅឥលូវមិនដូចសៀវភៅពីដើម ក្រសួងគេបោះពុម្ពឲ្យរៀន បង្រៀនអញ្ចឹងផង ហើយបង្រៀនតាមទេព្យកោសល្យរបស់គ្រូផង បញ្ចេញបញ្ចូលតាមសង្គម អប់រំតាមដែលគេណែនាំយើងជាគ្រូហ្នឹង។

ដានី: ក្មេងៗប៉ុនៗណា?

នុន: ប៉ុណ្ណេះ។

ដានី: អាយុ៧-៨ឆ្នាំ?

នុន: អាខ្លះ១១-១២ហើយ ក្មេងខ្លះអាយុចង់ប្រហែលគ្រូដែរហ្នឹងកាលជំនាន់ហ្នឹង ព្រោះមានសាលាមានអីណាកាលហ្នឹង ហើយដល់ពេលពិបាកពេក គ្រូជំនាន់ហ្នឹងអត់មានអីផង ហើយយើងមានប្រាក់មានអីណា បាយខ្លួនឯងហើយបង្រៀនកូនគេសរសេរធ្យូងកាលជំនាន់ហ្នឹង។

ដានី: ពីណាអ្នកតាំងឲ្យពូបង្រៀន?

នុន: កាលហ្នឹងរដ្ឋប្រហារហើយ កើតខ្មែរក្រហមហើយ ខ្មែរក្រហមគេរៀបចំអញ្ចឹង។

ដានី: ខ្មែរក្រហមខាងភូមិខាងឃុំគេអ្នករៀបចំ ឬក៏មានអ្នកមកពីខាងណា?

នុន: ភូមិគេនៅហ្នឹងហ្នង ភូមិគេរៀបចំហ្នង បណ្ដាញគេមិនដឹងពីណាពីណើ ហើយគេចាត់តាំងអញ្ចឹងចេះតែបង្រៀនទៅ។

ដានី:	ហើយក្មេងៗច្រើនទេ?

ឆុនៈ	ច្រើន ហើយម្យ៉ាងម៉ែឪខ្ញុំកាលហ្នឹងថា គេមិនរិះគន់យើងថាឲ្យទៅវត្តទៅអីណា ម៉ែឪចង់ឲ្យកូននៅជាមួយជាប់ចេះតែឲ្យបង្រៀនទៅ ដល់ពេលខ្ញុំពិបាកពេកខ្ញុំឈប់ហ្នងទៅ បង្រៀនបាន២ឆ្នាំខ្ញុំទៅធ្វើវត្តហ្នឹងគេទៅ ។

ដានី:	ឆ្នាំណាដែលពូចេញធ្វើវត្ត?

ឆុនៈ	ឆ្នាំ៧២ ខែ៦ ។

ដានី:	ហើយពូស្ម័គ្រចិត្តចូលធ្វើកងទ័ពហ្នង?

ឆុនៈ	បាទ! កាលហ្នឹងបើមិនស្ម័គ្រចិត្តក៏គេរិះគន់យើងដែរ រិះគន់រឿងម៉ែឪថាទុកកូននៅ មិនឲ្យចូលធ្វើវត្តធ្វើអីនឹងគេណា អាហ្នឹងគេរិះគន់យើងដែរថាម៉ែឪក៏ពិបាកដែរ អាហ្នឹងគេមិនទាន់ថ្កល់ទោសមែនទែនទេណ៎ា ជំនាន់ឆ្នាំ៧២ ដល់ពេលឆ្នាំ៧៣សុទ្ធតែមានមេទិញណ៎ាថ្កល់ទោសយុវជនមិនចូលបម្រើកងទ័ព អាហ្នឹងសុទ្ធតែបោសអស់ហើយជំនាន់ហ្នឹង តែខ្ញុំចូលមុន ខ្ញុំធ្វើពិបាកទេ ហើយធ្វើគ្រូមិនមែនបង្រៀនតែមួយថ្នាក់ណា ហើយថ្នាក់តូចៗផងធំៗផង ពីរថ្នាក់តែឯង ពិបាកណាស់គិតទៅ ហើយខ្ជិលណាស់ជៀសទៅវត្តមិនរួច ហើយគោលបំណងគេជំរុញអញ្ចឹងហើយ គេធ្វើយ៉ាងណាកុំឲ្យយើងនៅជាប់ជាមួយឪពុកម្តាយ គេឲ្យទៅវត្តទាំងអស់ ។

ដានី:	ចុះពូកាលយើងចូលទៅនៅវត្តដំបូង យើងទៅនៅណាទៅ?

ឆុនៈ	ខ្ញុំមែន?

ដានី:	បាទ!

ឆុនៈ	ខ្ញុំចូលអត់នៅឃុំនៅអីទេ ខ្ញុំទៅស្រុកហ្នង តែទៅដំបូងអត់នៅវត្តស្រុកទេ គេឲ្យទៅនៅកន្លែងមន្ទីរស្រុកមន្ទីរអី ហើយបានឡើងបន្តទៅវត្តទៀត ។

ដានី:	កន្លែងមន្ទីរស្រុកណា ស្រុកដងទង់ហ្នឹង?

ឆុនៈ	អត់ទេ ស្រុកកំពង់ត្រាចហ្នឹង កាលហ្នឹងអត់ទាន់មានស្រុកដងទង់ទេ នៅក្នុងស្រុកកំពង់ត្រាច ។

ដានី:	ដល់ពេលចូលវត្តហើយយ៉ាងម៉េចទៀត គេឲ្យយើងហាត់កងវត្តដែរឬក៏អត់ទេ?

ឆុនៈ	ហាត់វត្ត ។

ដានី:	ហាត់នៅកន្លែងណាទៅ?

ឆុនៈ	ហាត់នៅកន្លែងភូមិប្រជាជនក្រោយៗ មិនទាន់ចូលសមរភូមិទេ កាលហ្នឹងគេឲ្យហាត់នៅក្រោយៗ គេឲ្យហាត់បច្ចេកទេស ។

ដានី: ហាត់រយៈពេលប៉ុន្មាន?

ឆុន: មិនដឹងរយៈពេលប៉ុន្មានទេ គេឲ្យរើកកុំរ៉ឺនហើយបានគេឲ្យទៅវៃ ។

ដានី: អញ្ចឹងដល់ពេលពូនៅកន្លែងមន្ទីរស្រុកកំពង់ត្រាចហ្នឹងហាត់កងទ័ពហើយ ដល់ពេលហើយឆ្នាំណាបានចេញពីហ្នឹង?

ឆុន: អត់ដឹងឆ្នាំប៉ុន្មានទេព្រោះមិនចាំ មិនដឹងជា៧០ប៉ុន្មានទេ តែនៅមិនយូទេ បែបរង្វង់ឆ្នាំ៧៣ហ្នឹង កាលជំនាន់ឆ្នាំ៧៣ហ្នឹង ខ្មែរក្រហមវៃគ្នាជាមួយកងទ័ពវៀតណាម វៀតណាមមកពីខាងជើង ដែលគេហៅថាយួមកម្មុយនីសហ្នឹង ហើយខ្ញុំចូលទ័ពស្រុកហើយទៅវៃជាមួយយួនជាមួយអីហ្នឹង វៃជាមួយវៀតណាមខាងជើងហ្នឹង ។

ដានី: វៃដេញឲ្យទៅស្រុកវាវិញ?

ឆុន: ហ្នឹងហើយ វៃចចារ១មិនដឹងជាស្អីទេ ព្រោះយើងកូន១គេដែរអត់ដឹង គេឲ្យវៃ១ គេឲ្យឈប់១ វៃចចារ១ម្តុំកំពតហ្នឹង ដល់ពេលវៃហើយកៀរវា ហើយចែកតំបន់ឲ្យវាទៅនៅកៀកយួនខាងត្បូងហ្នុង នៅព្រំដែន អត់ដឹងដែរកាលហ្នឹង គេឲ្យវៃ១ទៅព្រោះកូនគេ ។

ដានី: អញ្ចឹងកាលហ្នឹងពូចេញពីទ័ពស្រុកនូវ?

ឆុន: នៅក្នុងទ័ពស្រុកហ្នឹងកាលវៃជាមួយវៀតណាមហ្នឹង ។

ដានី: វៃឆ្នាំ៧៣ហ្នឹងវៃ ហើយយ៉ាងម៉េចទៀតទៅ ពេលដែលយើងវៃជាមួយវៀតណាមហ្នឹង?

ឆុន: ដល់ពេលក្រោយមកយើងត្រូវគ្នាវិញ ដែលថាយើងចចារហ្នឹង ហើយពួកវៀតណាមហ្នឹងទៅនៅកៀកព្រំដែនយើង ព្រំដែនកំពតហ្នឹង ព្រំដែនយួនជាប់គ្នា ឲ្យវាទៅហ្នឹងទៅ ក្រោយមកត្រូវគ្នាវិញខ្មែរគ្នាឯងវិញ កាលវៃជាមួយទាហានលន់ នល់ណុ៎ ។

ដានី: វៃជាមួយទាហានលន់ នល់វិញ?

ឆុន: បាទ! វៃនៅមួយជួរកំពតហ្នឹង ។

ដានី: ពូនៅកងទ័ពស្រុកដដែល?

ឆុន: បាទ!

ដានី: កាលហ្នឹងកងទ័ពស្រុកមានប៉ុន្មាននាក់ទៅ?

ឆុន: ច្រើនណាស់ខ្ញុំចាំមិនអស់ទេ ច្រើនវរៈណាស់ ។

ដានី: ច្រើនវរៈដែរ?

ឆុន: បាទ! ច្រើនវរៈណាស់ មាន៤-៥វរៈ ។

ដានី: វរៈសេនាតូចមែន?

ឆុន: បាទ!

ដានីៈ ពីណាគេប្រធាននៅទ័ពស្រុកហ្នឹង?

ឆុនៈ ប្រធានធំមិនដឹងដែរ តែកាលហ្នឹងរចនាសម្ព័ន្ធដូចរដ្ឋបាលក៏គ្រប់គ្រងហ្នឹង ហើយអ្នកបញ្ជាទ័ពក៏ហ្នឹងដែរ ដូចជាចៅហ្វាយស្រុកហ្នឹងដែរ ។

ដានីៈ ចៅហ្វាយស្រុកកំពង់ត្រាចហ្នឹង?

ឆុនៈ បាទ! ឈ្មោះ តាសួង ហើយតាសៀន ហ្នឹងបងប្អូនគាត់បង្កើត ។

ដានីៈ គាត់ក្តាប់ទាំងពីរ?

ឆុនៈ ហ្នឹងហើយ ទាំងរដ្ឋបាល ទាំងទ័ពផង តែគ្រាន់តែមានមេបន្តបន្ទាប់មកនៅសមរភូមិ ។

ដានីៈ ចុះបន្ទាប់ពីវ៉ៃវៀតណាមខាងជើងហើយ ហើយមកវ៉ៃជាមួយទាហានលន់ នល់វិញ?

ឆុនៈ បាទ!

ដានីៈ ឆ្នាំណាដែលយើងវ៉ៃជាមួយទាហាន លន់ នល់?

ឆុនៈ ឆ្នាំ៧៣ដូចតែគ្នាហ្នឹង ៧៣-៧៤ហ្នឹងវ៉ៃរហូតទាល់តែដល់ឆ្នាំ៧៥ហ្នឹង វ៉ៃជាមួយទាហានលន់ នល់រហូត កាលហ្នឹងវ៉ៃឆ្នាំប៉ុន្មានទេ ចេញពីទ័ពស្រុកគេឲ្យឡើងទៅទ័ពតំបន់ ទ័ពខេត្ត ។

ដានីៈ ឆ្នាំណាដែលពូឡើងទៅទ័ពខេត្ត?

ឆុនៈ ខ្ញុំមិនចាំទេ តែឡើងទៅទ័ពខេត្តហ្នឹងមិនយូទេ បានប៉ុន្មានខែហ្នឹង ហើយគេបញ្ជូនមកទ័ពភូមិភាគទៀត ។

ដានីៈ ទ័ពតំបន់គេហៅតំបន់ប៉ុន្មានកាលហ្នឹង?

ឆុនៈ តំបន់៣៥ ហើយស្រុកលេខ៧៧ ។

ដានីៈ ដល់ពេលហើយនៅកងទ័ពតំបន់បានប្រហែលជារយៈ ពេលប៉ុន្មានខែ?

ឆុនៈ មិនដឹងជាប៉ុន្មានខែទេ ប្រហែលជា៣-៤ខែ ហើយគេបញ្ជូនមកទ័ពភូមភាគទៀត ឡើងពីទ័ពភូមិភាគហ្នឹងទៅវ៉ៃនៅម៉ាដូររោងចក្រប្រេងកាត ម៉ាដូរកំពង់សោម គិតទៅទ័ពគេចល័តរហូត ។

ដានីៈ ទ័ពភូមិភាគណា?

ឆុនៈ ភូមិភាគនារតី ។

ដានីៈ អញ្ចឹងដល់ពេលពូឡើងមកដល់ទ័ពតំបន់ ទ័ពភូមិភាគយើងនៅក្នុងកងពលហើយ ឬគេអត់ទាន់មានកងពលទេ?

ឆុនៈ មានកងពលទី៣ ។

ដានីៈ អញ្ចឹងពូនៅខាងកងពលទី៣?

ឆុនៈ បាទ! ដល់ពេលបានពាឆ្នាំគេផ្លាស់លេខកងពលទៀត គេផ្លាស់កងពលលេខ១៦៨វិញ ហើយមានមាស មុត ហ្នឹងជាអ្នកគ្រប់គ្រង មាស មុត ហ្នឹងប្រចាំនៅក្រុងកំពង់សោមហ្នឹង គ្រប់គ្រងទាំងទ័ពនៅលើកោះដើងគោកហើយនឹងដើងទឹកហ្នឹង ។

ដានីៈ ពូ ខ្ញុំចង់បញ្ជាក់ពូបន្តិច កាលពូនៅកងពលទី៣ហ្នឹងពីណាគេប្រធាន?

ឆុនៈ មាស មុត ហ្នឹង ។

ដានីៈ មាស មុត ហ្នឹងដែរ?

ឆុនៈ បាទ!

ដានីៈ កាលហ្នឹងកងពលទី៣គ្នាច្រើន?

ឆុនៈ ច្រើនណាស់ ស្គាល់មិនអស់ទេ ។

ដានីៈ មានប៉ុន្មានវរៈសេនាធំទៅ?

ឆុនៈ មានវរៈសេនាធំ ហើយកាលហ្នឹងនៅក្នុងវរៈសេនាធំដែរ តែភ្លេចលេខបាត់ហើយ ។

ដានីៈ វរៈសេនាធំហ្នឹងឈ្មោះអី?

ឆុនៈ ឈ្មោះ យ៉ាន ។

ដានីៈ ឈ្មោះ យ៉ាន ហ្នឹងវរៈសេនាធំរបស់ពូ?

ឆុនៈ យ៉ាង ហ្នឹងប្រធាន ហើយតាមុត មាន តាស្រស់ មួយទៀត ហើយ តាស្រស់ ហ្នឹងខ្មៅ ហើយមានមួយទៀតតែមិនដឹងពីណាគេទេ ស្គាល់តែ តាយ៉ាន ហ្នឹងប្រធាន ហើយមាស មុត នឹងតាស្រស់ ។

ដានីៈ ចុះគណៈកងពលមាន តាមុត ហើយពីណាគេទៀត?

ឆុនៈ មិនដឹងពីណាគេទេ មេធំៗហ្នឹងខ្ញុំមិនសូវស្គាល់ទេ មានតាមុត ហើយក្រោយមកដល់ជិតាន់ ពាឆ្នាំហើយបានស្គាល់ច្បាស់ មាន តាឌឹម មួយទៀត ហើយគាត់មកពីភូមិភាគបូព៌ា មក ប្រទ្បូកគ្នា កាលហ្នឹងគេរៀបកងទ័ពដើងទឹកណាំ ។

ដានីៈ អញ្ចឹងពូ ដល់ពេលបែកឆ្នាំ៧៥?

ឆុនៈ បែកឆ្នាំ៧៥ខ្ញុំមកនៅកំពង់សោម ។

ដានីៈ បែកឆ្នាំ៧៥ភ្លាមពូមកនៅកំពង់សោមហ្នង?

ឆុនៈ បាទ! កាលវ៉ៃបែកឆ្នាំ៧៥ហ្នឹង ខ្ញុំវ៉ៃចូលពីលិចដល់ចោមចៅនេះ ដល់គេថាបែកហើយ ដល់ ហើយគេថាផ្លូវទៅកំពង់សោមទៅ ទៅទាំងយប់ កាលហ្នឹងកោះភ្នងអត់ទាន់បែក ដើរវាង កោះភ្នង គេបញ្ជាភ្លាមៗហ្នង ដើរទៅកំពង់សោម ដល់ពេលទៅមានដល់កំពង់សោមណាពួក ខ្ញុំ នៅមុំព្រលានយន្តហោះ ខ្លះគេទៅហួសទៅកំពង់សោម តែអង្គភាពខ្ញុំនៅហ្នឹង ។

ដានី: នៅកន្លែងកងកេង?

ឆុន: បាទ! នៅកន្លែងយន្តហោះកងកេងហ្នឹង ។

ដានី: នៅរយៈពេលប៉ុន្មានទៅ?

ឆុន: នៅយូដែរ ធ្វើស្រែធ្វើអីនៅហ្នឹងបានយូដែរ ដល់ពេលគេរៀបចំកងទ័ពយើងទឹកហ្នឹងបានគេហៅទៅរៀននៅកំពង់សោមជិតមួយខែ ។

ដានី: ខែណាឆ្នាំណាទៅ?

ឆុន: អត់ចាំទេ ។

ដានី: អញ្ចឹងដល់ពេលហ្នឹងគេហៅទៅរៀននៅកំពង់សោម?

ឆុន: បាទ! គេហៅទៅរៀននៅកំពង់សោម ទៅរៀនបច្ចេកទេសដែលយើងយកនាវាចម្បាំងមកពីប្រទេសចិនហ្នឹងណា៎ ដែលគេហៅថារៀនបច្ចេកទេសត្រៀម អាខ្លះគេទៅរៀននៅចិន តែខ្ញុំអត់ទេ ហើយរៀនហ្នឹងមិនមែនរៀនបច្ចេកទេសអីទេ រៀននយោបាយហ្នឹង ដល់ពេលអញ្ចឹងទៅគេមើលថាអ្នកណាមានប្រវត្តរូបម៉េចៗ ហើយទៅរៀនគ្នាច្រើនណាស់នៅរោងកុនកំពង់សោមហ្នឹង តែដល់ពេលអ្នកណាត្រូវមកធ្វើរដើងគឺត្រូវមកធ្វើរដើង អ្នកណាដែលគេត្រូវស្រាវជ្រាវប្រវត្តិរូប មិនដឹងគេចង់ម៉េចខ្ញុំមិនដឹងដែរ ហើយខ្ញុំហ្នឹងបានគេឲ្យនៅចាំកងដើងទឹកហ្នឹងទៅ តែអត់មានរៀនបច្ចេកទេសអីផង រៀននយោបាយហ្នុង ។

ដានី: រៀននៅកន្លែងណា?

ឆុន: រៀនហ្នឹង តាមុត ជាអ្នកបង្រៀន រៀននៅរោងកុនកំពង់សោមហ្នុង រោងកុនគេពីដើមមិនដឹងរោងកុនអីទេខ្ញុំមិនបានមើលផង តែគ្រាន់តែដឹងថាកន្លែងហ្នឹងជាកន្លែងរោងកុន ។

ដានី: ហើយ តាមុត អ្នកបង្រៀនផ្ទាល់ហ្នុង?

ឆុន: បាទ!

ដានី: កាលហ្នឹងមករៀននៅហ្នឹងទាំងអស់គ្នាមែន?

ឆុន: រៀនគ្នាច្រើនណាស់ តែគេឲ្យវិលទៅអង្គភាពវិញ អ្នកណាដែលត្រូវនៅគឺនៅហើយអ្នកណាត្រូវទៅគឺទៅ ហើយអាខ្លះគេវិលទៅអង្គភាពវិញ ។

ដានី: វិលទៅអង្គភាពនៅណា?

ឆុន: អង្គភាពនៅច្រើនកន្លែងណាស់ ខ្លះនៅកោះ ហើយខ្លះទៀតនៅម៉ាជួរព្រលានយន្តហោះកងកេងហ្នឹង នៅនោះមួយវរៈ ហើយនៅនោះមួយអនុសេនាធំអញ្ចឹងទៅ តែដល់ពេលរៀនគឺនៅកងពលតែមួយ គេហៅរៀនគឺមូលគ្នា ។

ដានី: កាលហ្នឹងកងពលគេចាប់ផ្តើមផ្លាស់លេខពីកងពលទី៣មក១៦៤ពេលណា?

ឆុនៈ ដែលទៅនៅកោះនៅអីហ្នឹង កងពល១៦៨មួយគេហៅកងជើងទឹកទាំងអស់ហ្នឹង ឲ្យតែអ្នកដែលនៅលើកោះក្នុងសមុទ្រណា៎ នៅលើគោកក៏អញ្ចឹងដែរ កងពលតែមួយគេគ្រប់គ្រងតែកងជើងទឹកដែលមាននាវាចម្បាំងនៅហ្នឹងមានតែវរៈសេនាធំទេ ។

ដានីៈ ពីណាគេហ្នឹង ពីណាគេគ្រប់គ្រងអាហ្នឹង?

ឆុនៈ ឈ្មោះអីទេ វរៈសេនាធំ ឈ្មោះ រឿន តែឥលូវស្លាប់បាត់ហើយ ។

ដានីៈ តារឿន ហ្នឹងគាត់ស្លាប់ហើយ?

ឆុនៈ ស្លាប់ហើយ ទៅនៅដល់យើងជំនាន់វៀតណាមយើង៧៩ គាត់ទៅគ្រប់គ្រងទ័ពនៅខាងស៊ីសុផុន ហើយគាត់ស្លាប់នៅស៊ីសុផុន ។

ដានីៈ ហើយ តាសេង?

ឆុនៈ តាសេង ក៏ស្លាប់ ។

ដានីៈ ប៉ុន្តែ តាសេង គាត់គ្រប់គ្រងខាងអីវិញ?

ឆុនៈ តាសេង គាត់នៅគ្រប់គ្រងសមរភូមិខាងកោះកុងហ្នឹង ។

ដានីៈ នៅខាងកោះកុងវិញ?

ឆុនៈ បាទ! តាសេង កាលជំនាន់៣ឆ្នាំនៅហ្នឹងដែរ នៅកងជើងទឹកដែរ ។

ដានីៈ គាត់ខាងអីគេកាលហ្នឹង?

ឆុនៈ គាត់វរៈសេនាធំដែរកាលហ្នឹង ។

ដានីៈ វរៈសេនាធំខាង?

ឆុនៈ ខាងជើងទឹក ។

ដានីៈ ចុះកាលហ្នឹងគណៈកងពលមាន តាមាស មុត ហើយនឹង ឌឹម?

ឆុនៈ បាទ!

ដានីៈ ហើយមាស មុត ហ្នឹងមកពីខាងបូព៌ា?

ឆុនៈ បាទ!

ដានីៈ អញ្ចឹងបានន័យថាកងទ័ព១៦៨ហ្នឹងមានកងពលទី៣ផង ហើយនឹងមានបញ្ចូលមកពីបូព៌ាទៀត ។

ឆុនៈ បូព៌ាហ្នឹងក្រោយពេលដែលគេរៀបកងជើងទឹកហ្នឹងគេយកពីបូព៌ាមកមាន៧០០នាក់ ហើយយកមកបូកខាងនារតីនេះ គេច្របាច់ចូលគ្នាដើម្បីបង្កើតជាកងជើងទឹកហ្នឹង ដល់ពេលមកគ្មាន មិនដឹងជាស្អី១ច្របូលច្របល់ អត់ត្រូវគ្នាផងហ្នឹង មកច្របូលច្របល់ឈ្លោះគ្នារហូត ។

ដានី៖ ចុះខាងនារីមានប៉ុន្មាននាក់?

គុន៖ ខ្ញុំចាំមិនបានទេ តែខ្ញុំដឹងថាមកពីភូមិភាគបូព៌ាមកពីកងជើងទឹកហ្នឹងដំបូងមាន៧០០នាក់ តែក្រោយមករត់ទៅវិញរួចខ្លះ ហើយគេចាប់មកវិញយកទៅលុតដំអីណាណីខ្ញុំមិនដឹងដែរ តែចុងបញ្ចប់ពួកមកពីភូមិភាគបូព៌ាហ្នឹងដកចេញទាំងអស់អត់មានឲ្យនៅទេ ។

ដានី៖ ហើយគណៈកងពលមាន តាមុត មានតាឌឹម ហើយមានពីណាគេទៀត?

គុន៖ មិនដឹងអ្នកណាមួយទៀតទេ ព្រោះខ្ញុំចាំមិនច្បាស់ទេ ដឹងមានតែពីរហ្នឹង ហើយ តាឌឹម ហ្នឹងអ្នកនាំកម្លាំងហ្នឹងមក ។

ដានី៖ អ្នកនាំកម្លាំងមកពីបូព៌ាមក?

គុន៖ បាទ! ដល់ពេលក្រោយៗមក តាឌឹម ហ្នឹងក៏គេដកចេញដែរ ។

ដានី៖ គេដកចេញដែរ?

គុន៖ បាទ! ដកទាំងមេ ដកទាំងកូនហ្នុង ដល់ពេលទំនាស់គ្នាខ្លាំងពេក ។

ដានី៖ ទំនាស់ជាមួយ តាមុត មែន?

គុន៖ ទំនាស់មិនមែនតែប្រព័ន្ធខាងលើទេ សូម្បីតែខាងក្រោមហ្នឹងក៏ទំនាស់គ្នាដែរ ហើយអត់ត្រូវគ្នាទេមិនដឹងម៉េច មិនដឹងគេមានបណ្ដាញគេម៉េច ទាស់គ្នាម៉េចរហូតហ្នុង នៅអត់ចូលគ្នាកើត ។

ដានី៖ ចុះកន្លែងគេលុតដំនៅកន្លែងណាទៅ?

គុន៖ មិនដឹងនៅណាណីទេ កាលទៅនៅកំពង់សោមមិនដែលដើរទេ ទាល់តែគេយកទៅកងទៅអី ហើយដកចេញពីហ្នឹងសុទ្ធតែទៅកងចល័ត ។

ដានី៖ កងចល័តនៅណា?

គុន៖ កងចល័តអាចនៅម្ដុំមួយជួរព្រលានយន្តហោះកងកេងហ្នឹង កងចល័តគេណា៎ កងចល័តហ្នឹង បើដកចេញពីណាដែលយើងធ្វើការផ្ការមិនល្អ ឬមួយគេតាមដានម៉េចគេយកមកដាក់កងចល័តហ្នឹង កងចល័តហ្នឹងធ្វើស្រែធ្វើអីធម្មតា ធ្វើស្រែធ្វើអីស្រេចតែគេប្រើទេអាហ្នឹង ចូលដល់កងចល័តហើយគេថាចូលដល់ការលុតដំ ។

ដានី៖ ចុះពូនៅកងណាដល់ពេលចូលហ្នឹង?

គុន៖ ខ្ញុំនៅកងពល១៦៤ហ្នឹងដដែល ។

ដានី៖ កងពល១៦៤តែយើងនៅផ្នែកណាមួយទៅ ផ្នែកដូចថាវរៈសេនាធំ ឬក៏វរៈសេនាតូច?

គុន៖ អាហ្នឹងវាគ្រប់គ្រងដោយវរៈសេនាធំហើយ តាឿន ហ្នឹង ។

ដានី៖ អញ្ចឹងពូនៅក្នុងវរៈសេនាធំរបស់ តាសារឿន ហ្នឹងដែលមានកប៉ាល់ចម្បាំងមានអីហ្នឹង ជើងទឹកហ្នឹង?

ឆុន៖ ហ្នឹងហើយ ។

ដានី៖ អញ្ចឹងពូនៅក្នុងទឹកហ្នុង?

ឆុន៖ បាទ!

ដានី៖ ពូនៅណា?

ឆុន៖ ខ្ញុំនៅយូជាងគេគឺនៅខេត្តកោះកុង ។

ដានី៖ នៅកោះកុង?

ឆុន៖ ប្រចាំការនៅហ្នឹង ។

ដានី៖ ចុះកាលជំនាន់ម៉ាយីកេអាមេរិចកាំងមកកាំងតាងអីពូមានដឹងទេ ការយើងបាញ់គ្នា?

ឆុន៖ កាលយើងចាប់ហ្នឹងមែន?

ដានី៖ បាទ!

ឆុន៖ អាហ្នឹងខ្ញុំអត់ទាន់នេះផង ខ្ញុំអត់ទាន់នៅកងជើងទឹកផង កាលហ្នឹងខ្ញុំនៅលើគោកនៅឡើយហ្នឹង ។

ដានី៖ គេបាញ់គ្នា ហើយយន្តហោះអាមេរិចកាំង?

ឆុន៖ យន្តហោះអាមេរិចកាំងទម្លាក់មក ហើយព្រលានយន្តហោះកងកេងមកទម្លាក់ដែរហ្នឹង ហើយខ្ញុំនៅក្បែហ្នឹងដែរហ្នឹង ។

ដានី៖ ប៉ុន្តែកាលហ្នឹងពូអត់ទាន់ទៅធ្វើកងជើងទឹកទេ?

ឆុន៖ នៅទេ ខ្ញុំនៅស្មើរជើងហ្នឹង ។

ដានី៖ កាលហ្នឹងនៅណា?

ឆុន៖ នៅជិតព្រលានយន្តហោះកងកេងហ្នឹង នៅខាងត្បូងហ្នឹង ។

ដានី៖ កាលហ្នឹងកំពង់ដែគេចតកាណូតចតអីនៅណា នៅរៀមមែន?

ឆុន៖ នៅរៀមគេហៅដែយោធាគេ ដែកប៉ាល់យោធា កប៉ាល់ចម្បាំងណា៎ ។

ដានី៖ បាទ!

ឆុន៖ តែដែដឹកទំនិញអី ហើយបរទេសនាំចូលមករបស់របរអីអាហ្នឹងដែកំពង់សោម ។

ដានី៖ ចុះដែមួយទៀតនៅអូរឈើទាល?

ឆុន៖ អូរឈើទាលហ្នឹងទើបតែកើតនៅជំនាន់ហ្នឹងដែរហ្នឹង ជំនាន់រៀបកងជើងទឹក ជំនាន់ខ្មែរក្រហមហ្នឹង អូរឈើទាលហ្នឹងកើតក្រោយទេ ។

ដានី:	គេសម្រាប់ធ្វើអីដែរនៅអូរឈើទាលហ្នឹង ។

ឆុន:	ដែហ្នឹងសម្រាប់តែចតកប៉ាល់យោធាហ្នឹង ។

ដានី:	ចតកប៉ាល់យោធា?

ឆុន:	បាទ! គេរបៀបថាលាក់ គេមិនបើកចំហរ ។

ដានី:	ដែហ្នឹងធំឬក៏តូច?

ឆុន:	ដែឈើតូចហ្នឹង បើដែធំហ្មងពីដើមមានតែវៀម ហើយវៀមកប៉ាល់យោធាក៏នៅដែរ ។

ដានី:	កាលខ្ញុំជួបពូ ពូហ្នឹងគាត់ថាមានដែមួយទៀតដែលគេកំពង់តែសាងសង់នៅសម័យ៣ឆ្នាំហ្នឹងដែរ នៅខាងស្ទឹងហាវ?

ឆុន:	អាហ្នឹងគ្រាន់តែគម្រោងរបស់ចិន គេធ្វើដែរតែទើបតែធ្វើបានបន្តិចហ្នឹង មិនទាន់បានចតបានអីស្រួលបួលផង គ្រាន់តែមានគម្រោងធ្វើ ដល់ពេលស្រុកយើងអញ្ចឹងទៅ គម្រោងដែនការរបស់ចិន អាហ្នឹងគម្រោងរបស់គេធំណាស់ បើថាធ្វើគេធ្វើមាំហ្មង តែមានទាន់បានធ្វើណា គេទើបតែធ្វើបានបន្តិចហ្នឹង ។

ដានី:	អញ្ចឹងទើបតែធ្វើបានបន្តិចទេ?

ឆុន:	ធ្វើបានបន្តិចហ្នឹង គេទើបតែចាក់ដីចូលបានបន្តិចហ្នឹង គេកំពុងតែស្រាវជ្រាវ ។

ដានី:	ប៉ុន្តែកាលហ្នឹងពូមានបានទៅធ្វើទេ?

ឆុន:	អត់ទេ ។

ដានី:	ក្រុមណាដែលទៅធ្វើហ្នឹង ចិនឬខាងកងទ័ពយើងធ្វើ?

ឆុន:	កាលហ្នឹងមិនទាន់បានធ្វើស្រួលបួលណា គ្រាន់តែគេស្រាវជ្រាវមានចិនមានខ្មែរយើង គេចុះមុជមើលបាតសមុទ្រមើលអី ហើយគម្រោងគេមិនដឹងគេធ្វើម៉េច ពិនិត្យស្អីម៉េចៗខ្ញុំអត់ដឹងទេ ហើយឃើញចិនគេដើរបោស អាណាទុំក្រហមៗហ្នឹង ព្រោះកាលហ្នឹងយើងបើមិនមានជំនាញអីនៅហ្នឹងក៏យើងអត់ដឹងថាគេធ្វើអីនៅត្រង់ណាអីត្រង់ណាដែរ បើថាអ្នកគេចូលការងារគេហ្នឹងបានគេដឹង បើថាយើងនៅខាងក្រៅគ្រាន់តែឃើញគេបោសគេអី តែអត់ដឹងថាទិសដៅគេយ៉ាងម៉េចអីយ៉ាងម៉េចទេ ។

ដានី:	ប៉ុន្តែពូធ្លាប់បានទៅឃើញទេ?

ឆុន:	ឃើញ ព្រោះខ្ញុំធ្លាប់ទៅហ្នឹង ។

ដានី:	ពូធ្លាប់ទៅហ្នឹងដែរ?

ឆុន:	ធ្លាប់ទៅនៅហ្នឹង ។

ដានី:	កន្លែងណាដែលគេប្រុងធ្វើដែហ្នឹង?

ភុនៈ គេហៅស្ទឹងហាវៗ ទោះបីប្រាប់ក៏មិនដឹងថានៅត្រង់ណាដែរ ។

ដានីៈ ប៉ុន្តែស្ទឹងហាវវាធំ ហើយមកដល់កន្លែងហ្នឹងគេហាវអីទៅ?

ភុនៈ ហ្នឹងហើយ ស្ទឹងហ្នឹង ចំស្ទឹងហាវហ្នឹង ការពិតគ្មានភូមិមានអីផងហ្នឹង ។

ដានីៈ អត់មានភូមិទេ?

ភុនៈ បាទ! កន្លែងហ្នឹងសមុទ្រវាវាងឆកចូលបើយើងមើលតាមផែនទីក៏ដឹងថាឆកចូលដែរកន្លែងហ្នឹង អាហ្នឹងគម្រោងគេ គេបម្រុងថាគេធ្វើទៅសម្រាប់លាក់នាវាចម្បាំងចូលទៅម្តុំហ្នឹងសមុទ្រវាវាងឆកចូលទៅជ្រៅជាងគេកន្លែងហ្នឹង ។

ដានីៈ ពូធ្លាប់ទៅកន្លែងហ្នឹងដែរអញ្ចឹង?

ភុនៈ ធ្លាប់ទៅមើល ធ្លាប់ទៅឃើញ ហើយធ្លាប់ទៅនៅកន្លែងហ្នឹងដែរ ។

ដានីៈ ហើយដែលឃើញចិនគេមកធ្វើដែរអត់?

ភុនៈ ឃើញ កាលហ្នឹងគេកែនទ័ពដែលមិនទាន់មានទ័ពមានអីនៅហ្នឹង គេកែនទៅធ្វើរោងធ្វើអីសម្រាប់ឲ្យកម្មករ កាលហ្នឹងគេថាគេធ្វើផ្លូវរថភ្លើងទៅដល់ហ្នឹង គេមិនយកកម្មករទៅហ្នឹងឲ្យទៅធ្វើរោងធ្វើអី ធ្វើរោងវែងៗ ហើយយកទ័ពទៅធ្វើណា គេថាសម្រាប់កម្មករដែលមកធ្វើផ្លូវរទេះភ្លើងហ្នឹងមកស្នាក់ តែឃើញមកដែរហ្នឹង មិនដឹងប៉ុន្មានរយទេ មកប៉ុន្មានថ្ងៃដែរ តែមិនដឹងថាគេបម្រុងធ្វើអីទេ ហើយមិនដឹងទៅណាបាត់វិញ ។

ដានីៈ កម្មករហ្នឹងមែនកងទ័ពទេ?

ភុនៈ មិនមែនពលទ័ពទេ កម្មករ តែខ្មែរយើងហ្នឹង ។

ដានីៈ ប៉ុន្តែកន្លែងវ៉ៃថ្ម យកថ្មយកអីមកធ្វើហ្នឹងកន្លែងណា?

ភុនៈ អត់ទាន់មានឃើញវ៉ៃឃើញអីផង ។

ដានីៈ អត់ទាន់មានឃើញទេ?

ភុនៈ បាទ! បើថាផ្លូវដែលចេញបំបែកជាប់រោងចក្រប្រេងកាតហ្នឹង ទ័ពវ៉ៃថ្មខ្លួនឯងហ្នុង ហើយអត់មានបានធ្វើទេផ្លូវ ។

ដានីៈ វ៉ៃថ្ម?

ភុនៈ បាទ! វ៉ៃថ្មហ្នឹង មិនថាទ័ពមិនថាអីជំនាន់ហ្នឹងលុតដីទាំងអស់ ហើយទ័ពហ្នឹងក៏យ៉ាប់ដែរ ។

ដានីៈ លុតដីដែរ?

ភុនៈ បាទ! គេសុទ្ធតែកំណត់ ថ្មមុនដំបូងវ៉ៃ២នាក់អញ្ចឹងតែ៤ម៉ែត្រគីបទេ បើយើងវ៉ៃបានចេះតែដំឡើងរហូតដល់៦នាក់១២ម៉ែត្រគីប គេកំណត់ហ្នុង បើយើងនេះវេទនាណាស់ ហើយមានម៉ាស៊ីនខ្លួនម៉ាស៊ីនអីមកពីណា សុទ្ធតែមនុស្សបុកហ្នឹង ដែកប្រវែងហ្នឹងបុក ហើយអ្នក

បុកគេកំណត់មួយថ្ងៃរន្ធមួយម៉ែត្រ ព្រោះថ្ម មិនមែនងាយបុកទេលោកអើយ ហើយខ្ញុំមុនដំបូងបុក តែអាថ្មហ្នឹងវារឹងប្រហែលជា៣តឹកអីទេ ដល់ចូលទៅដល់បន្តិចវាមិនដូចដីណា៎ ដល់ពេលចូលទៅដល់ក្រោមបន្តិចវាឆាប់បានរន្ធទៅជ្រៅបន្តិច ។

ដានី: វារាងផុយៗដែរ?

ផុនៈ បាទ! វាបុកដាក់ទឹក បុកហើយគេដាក់ទឹក គេមានទឹកដបគេដាក់ បុកមួលៗ ហើយបើថាមុនដំបូងអត់ចេះបុកវេទនាណាស់ ។

ដានី: បែកដៃបែកជើង?

ផុនៈ បាទ! ដូចថាមុនដំបូងបុកទៅវារន្ធបីជ្រុង ដល់ហើយបុកជាប់ៗហ្នុង ដល់ពេលអញ្ចឹងគេបុកមួយក្រិតអញ្ចឹងទៅគេបង្វិលមួយជុំបានគេដក អញ្ចឹងបានរន្ធវាមូលណា អត់ជាប់ទេ ។

ដានី: បុកនៅកន្លែងណា?

ផុនៈ នៅខាងក្រោយរោងចក្រជាប់ហ្នឹង ក្បែររោងចក្រប្រេងកាតហ្នឹង ។

ដានី: ហើយកងទ័ពទៅបុកនៅកន្លែងហ្នឹងទាំងអស់?

ផុនៈ បុកហ្នឹង ហើយចុចរំសេវនៅហ្នឹង ។

ដានី: កងទ័ពសុទ្ធឬក៏មានប្រជាជនដែរ?

ផុនៈ អត់មានប្រជាជនទេកងទ័ពសុទ្ធ ។

ដានី: ហើយមានអ្នកលុតដី អ្នកដែលមានធ្វើខុសធ្វើអី?

ផុនៈ អត់មានលុតដីអីទេ គម្រោងគេ ផែនការគេឲ្យធ្វើអញ្ចឹងហ្នុង ។

ដានី: ចុះកងទ័ពដូចថាខុសវិន័យឬក៏មានបញ្ហាអីគេឲ្យទៅលុតដីនៅកន្លែងហ្នឹងដែរ?

ផុនៈ អត់ទេ ។

ដានី: មានកន្លែងផ្សេងទៀត?

ផុនៈ បាទ! មានកន្លែងផ្សេង ដែលគេថាទៅកន្លែងកងចល័ត ។

ដានី: ហើយចុះមានវត្តក្រោម តែខ្ញុំអត់ច្បាស់ព្រោះពូមួយគាត់និយាយថាមានវត្តក្រោមមួយកន្លែងដូចថាអ្នកដែលធ្វើខុសធ្វើអី?

ផុនៈ វត្តក្រោមនៅណា?

ដានី: គេហៅវត្តឥត្តញ្ញាណ?

ផុនៈ អត់ដឹង ពូដែរតែខ្ញុំអត់ដឹង ។

ដានី: កន្លែងហ្នឹងដូចថាអ្នកខុសអ្នកអីគេយកទៅដាក់នៅហ្នឹង?

ផុនៈ ខ្ញុំអត់ដែលដឹងទេ ។

ដានី៖ តែពូពុ្កដែរ?

ឆុន៖ ពុ្កដែរតែអត់ដែលដឹងទេ ហើយកន្លែងអញ្ជឹងបើយើងអត់មានការអីក៏យើងអត់ឲ្យយើងដើរ ទៅមើលដែរ អត់មានទៅចេញចូលអីបានរហេតរហូតទេ អាកន្លែងអញ្ជឹងៗគេគឺងរឹងយើង អត់មានការងាររអីអត់មានទៅបានទេ អត់មានទៅមើលទៅអីកើតទេ ។

ដានី៖ ប៉ុន្តែគ្រាន់តែពុ្កៗដែរ?

ឆុន៖ បាទ! រឿងជាក់ស្តែងថាវាម៉េចអីម៉េចនោះយើងអត់ដឹងទេ អាហ្នឹងថាមិនត្រូវទេ ។

ដានី៖ តែកន្លែងវៃថ្មហ្នឹងទូទៅហ្នុង?

ឆុន៖ បាទ! វៃទូទៅហ្នុង ។

ដានី៖ ពូវៃបានយូទេ?

ឆុន៖ យូដែរហ្នឹង វៃដល់មាននាវវាមកនៅបានឈប់ ។

ដានី៖ កាលហ្នឹងដំបូងយើងអត់មាននាវវាទេ?

ឆុន៖ អត់មានទេ ។

ដានី៖ អញ្ជឹងយើងមិនអាចចុះទៅក្នុងទឹកបានទេ?

ឆុន៖ ហ្នឹងហើយ ហើយគេឲ្យយើងនៅធ្វើការហ្នឹងទៅ ធ្វើការវៃថ្មផង ហើយជួនកាលគេឲ្យធ្វើ ស្រែផងមិនថាទ័ពមិនថាប្រជាជនទេ កន្លែងណាក៏ធ្វើដែរ អត់ទំនេរទេ សូម្បីតែទ័ពហ្នឹងក៏ អញ្ជឹងដែរ ។

ដានី៖ ហើយចុះពូ តាឌឹម ហើយកូនចៅគាត់៧០០នាក់ជាងហ្នឹង នៅឆ្នាំណាដែលខ្ចាតខ្ចាយគេដក ទៅវិញហើយគេយកទៅលុតដំហ្នឹង?

ឆុន៖ ខ្ញុំមិនចាំទេ ។

ដានី៖ មកបានយូទេ?

ឆុន៖ មកបានយូដែរហ្នឹង ហើយអ្នកខ្លះរត់គេចាប់មកវិញ ខ្ញុំមិនច្បាស់ទេ តែភាគច្រើនគេវៃ ចោលហើយ ។

ដានី៖ វៃចោល?

ឆុន៖ បាទ!

ដានី៖ តាឌឹម អីហ្នឹង?

ឆុន៖ តាឌឹម មិនដឹងទៅណាទេ ព្រោះគាត់មេកំពូលណា ហើយត្រឹមអនុសេនាធំ កងតូច ព្រោះ ប្រព័ន្ធរៀបកងដើងទឹកដំបូងយកពីថ្មើដើងទៅសុទ្ធតែពីត្រឹមអនុសេនាតូចទាំងអស់ ដល់ពេល មកពីភូមិភាគ៧០០ហ្នឹង គេជ្រើសរើសយកវណ្ណៈភាពល្អជំនាន់ហ្នឹង អ្នកក្រ ហើយខ្ញុំមានអី

ខ្ញុំគេកំណត់វណ្ណៈភាពជាកសិករ តែអាស្រ័យសកម្មភាពយើងដែរណា សកម្មភាពយើងល្អបានជាប់ហើយ ហើយថ្នាក់កណ្ដាលនេះគេអត់ទេ ។

ដានី: ហើយពូមានឋានៈអីកាលហ្នឹង?

ឆុន: ចេះតែមានហើយឋានៈតិចតួច ។

ដានី: ឋានៈអីគេកាលហ្នឹង?

ឆុន: ខ្ញុំនៅហ្នឹងអត់មានឋានៈអីផង កាលហ្នឹងវាគ្រប់គ្រងនៅតាមផ្នែកៗ នៅលើនាវាវាអញ្ចឹង ឧទាហរណ៍ថា នាវាមួយអញ្ចឹងវាមានប្រធានមានអនុប្រធាន ដូចថាប្រធានគេគ្រប់គ្រងខាងបើកបរអញ្ចឹងទៅ ហើយអនុប្រធានគេគ្រប់គ្រងខាងម៉ាស៊ីននៅលើនាវាអញ្ចឹងទៅ ហើយប្រធាននឹងអនុប្រធានគេគ្រប់គ្រងសមាជិកនៅលើហ្នឹងទាំងអស់ ទាំងប្រធានកាំភ្លើង ប្រធានអីទាំងអស់ណា៎ តែផ្នែកវាមានប្រធានៗ ហើយរួមមកគ្រប់គ្រងមានប្រធានធំមួយនឹងអនុប្រធានមួយ ។

ដានី: ហើយពូក្នុងផ្នែកអីគេ?

ឆុន: ខ្ញុំអនុប្រធាន មុនដំបូងគេឲ្យខ្ញុំទៅខាងបើកបរ ដល់ហើយគេដកមកវិញ ខ្ញុំទៅរៀនបើកបរបានមិនយូទេ ដល់ពេលអញ្ចឹងគេថាឲ្យទៅធ្វើអនុប្រធាននោះគេដកមកគ្រប់គ្រងខាងកាន់ម៉ាស៊ីនវិញទៅ ។

ដានី: ប៉ុន្មាននាក់នៅលើកប៉ាល់មួយហ្នឹង?

ឆុន: វាមានតិចមានច្រើនតាមកប៉ាល់ តែខ្ញុំមានបាននៅកប៉ាល់មកពីចិនអីទេ ខ្ញុំយកកប៉ាល់កាលជំនាន់... ។

ដានី: លន់ នល់?

ឆុន: បាទ!

ដានី: អាប៉េស៊ីអេសហ្នឹងមែន?

ឆុន: បាទ! គាត់ស្គាល់ប៉េស៊ីអេសហ្នឹងដែរ?

ដានី: ខ្ញុំឮពូៗគាត់និយាយប្រាប់ ។

ឆុន: ខ្ញុំនៅប៉េស៊ីអេសហ្នឹង ហើយនាវាហ្នឹងធ្វើនៅជប៉ុន ។

ដានី: អាហ្នឹងដូចជាប៉ុន្មាននាក់?

ឆុន: នៅប្រហែលជា៧-៨នាក់ ព្រោះកាំភ្លើងវាមានអីច្រើន មានតែ២ដុំហ្នឹងនៅខាងក្រោយមួយដុំ ហើយនៅខាងមុខមួយដុំ កងជើងទឹកវាត្រូវមាន២ ឧទាហរណ៍ថា មុខជំនាញមួយវាត្រូវមាន២-៣នាក់ ឧទាហរណ៍ពេលប្រយុទ្ធអីទៅត្រូវមានមួយកុំឲ្យអត់ស្លុះ ត្រូវមួយនៅ

សល់មួយទៀត របនាសម្ព័ន្ធរបស់គេ គេរៀបចំអញ្ជឹង ហើយសូម្បីតែអ្នកបើកបរក៏អញ្ចឹងដែរ ប្រធានគ្រប់គ្រងរួមបើកបរនៅហ្នឹងដែរ ។

ដានី: ហើយពួកបូព៌ានៅជាមួយយើងដែរ?

ឆុនៈ នៅជាមួយគ្នា ដល់ពេលក្រោយមកដកម្តងបន្តិចៗអស់ទៅ ។

ដានី: ហើយពួកថាគេយកទៅវៃចោលដែរ?

ឆុនៈ ខ្ញុំមិនកំណត់ថាគេវៃចោលទេ តែខ្ញុំថាបែប ។

ដានី: បែបគេយកទៅវៃចោល?

ឆុនៈ បាទ!

ដានី: ប៉ុន្តែមិនដែលឃើញគេយកទៅវៃចោលទេ?

ឆុនៈ អាខ្លះគេយកទៅលុតដីដែរ ទោះបីមិនវៃចោលក៏គេយកទៅលុតដីដែរ ។

ដានី: ហើយដូចកន្លែងដែលខ្ញុំនិយាយម៉េចហ្នឹងថាវត្តឥត្តញ្ញាណអីហ្នឹង អាវត្តហ្នឹងកន្លែងគេលុតដីនៅខាងតាមទួលលើ?

ឆុនៈ ធ្លាប់ឮដែរ តែខ្ញុំអត់ដែលចូលទេ ព្រោះយើងអត់មានការងារអីផង តែម្យ៉ាងទៀតខ្ញុំមិនសូវដែលបាននៅលើដីគោកហ្នឹងគេផង នៅតែក្នុងទឹក ហើយទៅប្រចាំការនៅកោះកុងរហូត ។

ដានី: ប្រចាំការនៅខាងកោះកុងវិញ?

ឆុនៈ បាទ!

ដានី: ចុះពួកាលយើង៧៧ យើងមិនវៃជាមួយយួន ហើយយើងវៃយ៉ាងម៉េចទៅបើយើងខាងជើងទឹក?

ឆុនៈ ៧៧មែន?

ដានី: កាល៧៧យើងមានសង្គ្រាមវៃជាមួយយួន?

ឆុនៈ ខ្ញុំអត់ដែលបានវៃទេ បើកប៉ាល់ដែលមកពីចិនហ្នឹងវាមានម៉ាកវា គេហៅថានាវវាការពា ហើយនាវវាការពាហ្នឹងវាសម្រាប់ល្បាតដែលគេបានវៃជាមួយយួន គេវៃមួយជួរកោះសេះទល់មុនកោះត្រល់ គេវៃជាមួយយួនគេវៃតែហ្នឹងទេ អត់មានវៃនៅណាទៀតទេ គេវៃហ្នឹងខ្ញុំនៅដៃ ។

ដានី: ចុះអាវៃចុចមីន?

ឆុនៈ អាចុចមីនហ្នឹងអត់មានវៃទេ ។

ដានី: អត់មានទេ?

ឆុនៈ អេ៎ អាចុចមីនបានវើដល់ចូលជិតដល់កំពង់សោមហើយបានវើ ព្រោះកាលវៀតណាមចូលហ្នឹងគេមិនទម្លាក់គ្រាប់បែក យន្តហោះទម្លាក់ ហើយអាពួកអាបាញ់មីនហ្នឹងវារបៀបដាច់ប្រព័ន្ធបញ្ជារ ហើយកាលហ្នឹងបើសិនជាអត់ពីរដ្ឋមន្ត្រីទេអត់មានចេញបានទេ នារវាហ្នឹងដល់ពេលទៅសួរមកពីភ្នំពេញមក កងពលអីក៏អត់សម្រេចចេញបានដែរ ហើយអញ្ចឹងទៅមិនដឹងស្អីជាស្អី គ្រាប់មីនហ្នឹងដកទុកឃ្លាំងដីគោកណា៎ ។

ដានីៈ អញ្ចឹងពូកាលជំនាន់នោះអត់មានបានវើជាមួយយួនទេ?

ឆុនៈ នៅកងជើងទឹកដូចគ្នាគេបានវើ ហើយនារវា...

ដានីៈ ប៉េស៊ីអេសហ្នឹង?

ឆុនៈ បាទ! អាហ្នឹងអត់មានត្រូវការទប់ទល់ជាមួយគេបានទេ ។

ដានីៈ ចុះដូចខាង យើងមានចាប់អីបានទេ ដូចពួកកងទ័ព ពួកយកសារ ហើយពួកនេសាទដែលគេមកយកការអី?

ឆុនៈ ចាប់តើ តែមិនដឹងស៊ើបការអី នៅកោះកុងខសង្សាហ៍ចាប់បានដែរ ។

ដានីៈ ពួកហ្នឹងពួកណា ពួកយួនឬមួយក៏ថៃ?

ឆុនៈ ពួកយួន ។

ដានីៈ ចាប់ហ្នឹងយើងឃើញរបៀបទំនងយ៉ាងម៉េច?

ឆុនៈ ខ្ញុំថាមិនមែនទាហានអីទេ ប្រជាជនអ្នករកស៊ីដែរ តែតាមដែលខ្ញុំនៅហ្នឹងគេឲ្យខ្ញុំយាម ហើយខ្ញុំសួរទេណា ហើយមួយទូកហ្នឹងវាមាន៣៣នាក់ ខ្មែរនៅខេត្តកំពតហ្នឹងវាមាន៣នាក់ ៣នាក់ហ្នឹងមានប្តីប្រពន្ធគាត់តែចំណាស់ដែរហើយ កាលហ្នឹងខ្ញុំនៅក្មេងហើយគាត់ចំណាស់ហើយមានកូនមួយទៅ ហើយគាត់អ្នកបើក ហើយខ្ញុំសួរទៅគាត់ថារត់ទៅថៃ ហើយមាសច្រើនណាស់នៅលើទូកហ្នឹង ។

ដានីៈ មាសច្រើន?

ឆុនៈ មាសច្រើនណាស់ ថារត់ទៅរកស៊ីនៅស្រុកថៃ តែដល់ពេលអញ្ចឹងគាត់ថាដេកនៅក្នុងស្រុកថៃ ដល់ពេលអញ្ចឹងមកពីយួនឬកោះស្អីមិនដឹងទេ រត់ទៅថៃដល់ពេលអញ្ចឹងមកចូលនៅកោះកុង ដល់ពេលអញ្ចឹងទៅមានពួកថាជាអីមើលគេហៅពួកខ្ញុំទៅ មានអីខ្ញុំចាប់មក៣៣នាក់ ។

ដានីៈ ៣៣នាក់ហ្នឹងមានខ្មែរ៣នាក់?

ឆុនៈ មានខ្មែរតែ៣នាក់ទេ ហើយខ្មែរហ្នឹងអ្នកបើក វារង្វេងតែរឿងត្រីវិស័យ វាស្មានតែកោះហ្នឹងកោះថៃ ។

ដានីៈ ដល់ហើយចូលមក?

ផុនៈ បាទ! ហើយកាលហ្នឹងជាខ្លាចស្រុកយួនហ្នឹងកើតសង្គ្រាម ដល់ពេលអញ្ចឹងគេចមករកស៊ីនៅស្រុកថៃ ។

ដានីៈ ពូភៀសខ្លួន?

ផុនៈ បាទ! ហើយមាសរាប់គីឡូ ។

ដានីៈ អញ្ចឹង៣៣នាក់ហ្នឹងមានខ្មែរតែ៣នាក់ទេ?

ផុនៈ បាទ!

ដានីៈ ហើយពូសួរនាំហ្នឹង សួរជាភាសាខ្មែរទេ?

ផុនៈ ជាភាសាខ្មែរ ព្រោះខ្មែរអ្នកបើក កាលហ្នឹងគេឲ្យខ្ញុំយាម ។

ដានីៈ គេឲ្យយាមទូកហ្នឹងមែន?

ផុនៈ បាទ!

ដានីៈ ពេលយើងចាប់បានហើយគេឲ្យយើងយាម?

ផុនៈ ចាប់បានគេចងដាក់លើទូកទាំងអស់ ហើយគេឲ្យយើងយាម ហើយគាត់ថាវង្វេង មកពីនោះមកដេកមួយយប់ហើយ អញ្ចឹងវង្វេង ហើយគាត់ថាដឹងថាកោះខ្មែរក៏អត់ចូលដែរ ស្មានតែកោះថៃ ។

ដានីៈ គាត់និយាយអញ្ចឹងដែរ?

ផុនៈ បាទ! អ្នកនៅលើកោះបាញ់ហើយក៏នៅមិនរត់ បាញ់អញ្ចឹងរត់ទៅឆ្ងាយហើយក៏បកមកវិញ ។

ដានីៈ កាលហ្នឹងឆ្នាំណា?

ផុនៈ មិនដឹងឆ្នាំប៉ុន្មានទេ ខ្ញុំមិនចាំទេរឿងឆ្នាំ ។

ដានីៈ ប្រហែលជា៧៧ឬ៧៨ កាលបែកយួនចូលមកហ្នឹង?

ផុនៈ ជិតបែកហើយ ។

ដានីៈ សល់ប្រហែលជាប៉ុន្មានខែទៀតបែក?

ផុនៈ មិនដឹងជាប៉ុន្មានទេ ។

ដានីៈ ចុះនៅក្នុងហ្នឹងមាសច្រើនទេ?

ផុនៈ មាសច្រើនណាស់ ។

ដានីៈ ហើយមាសហ្នឹងយើងយកឬមួយក៏គេបញ្ជូនទៅណា?

ផុនៈ គេថាទុកឲ្យអង្គការ ។

ដានីៈ ទុកឲ្យអង្គការ ហើយយើងអ្នកចាប់ហ្នឹងអត់បានទេ?

ផុនៈ អត់ទេ បើគេដឹងគេវ៉ៃចោលហ្នឹង អត់បានទេរបស់អញ្ចឹង ហើយយើងក៏មិនហ៊ានដែរ ។

ដានីៈ តែឥលូវដូចថាយើងចាប់យើងអាចយកបានខ្លះ?

ផុនៈ អត់ទេ អត់សោះ ។

ដានីៈ កាលជំនាន់ហ្នឹងអត់ហ៊ានទេ?

ផុនៈ អត់ មនុស្សគ្រង់ហ្នឹង ហើយខ្លាចស្លាប់ណាស់ ។

ដានីៈ គេប្រាប់អញ្ចឹងហ្នឹងឬក៏ធ្លាប់មានអ្នកយកទៅធ្វើអី?

ផុនៈ គេយកទៅវ៉ៃចោល ចេះតែខ្លាចទៅ ក្រែងលោគេដកយើងចេញទៅកន្លែងលុតដី អត់បាយ អត់ទឹកអី ។

ដានីៈ ចុះ៣៣នាក់ហ្នឹងគេយកទៅណាទៅ?

ផុនៈ គេបញ្ជូនទៅកំពង់សោម ។

ដានីៈ គេបញ្ជូនពីកំពង់សោមទៅកោះកុង?

ផុនៈ បាទ! បញ្ជូនទៅកន្លែងកងពល ។

ដានីៈ ហើយពូអ្នកបញ្ជូនមកដែរ?

ផុនៈ អត់ទេ ខ្ញុំអត់មកផង ជួនកាលកងពលគេឲ្យទូកទៅយកមក ។

ដានីៈ បញ្ជូនមកកន្លែងកងពលហ្នឹង?

ផុនៈ ហ្នឹងហើយ ហើយគេយកទៅធ្វើអីៗយើងអត់ហ៊ានថាទេ ។

ដានីៈ យើងអត់ដឹងទេ?

ផុនៈ បាទ! យើងអត់ដឹងទេ ។

ដានីៈ ដូចថាគេយកទៅកន្លែងដាក់គុក ហើយគេបញ្ជូនទៅណាក៏យើងមិនដឹង?

ផុនៈ អត់ដឹងទេ ។

ដានីៈ ចុះផ្សេងៗទៀតយើងមានដែលចាប់ ដូចថាពួកអ្នកនេសាទ ឬក៏ពួកអ្នកស៊ើបការយួនអីមាន ដែលទេ?

ផុនៈ អត់ទេ ។

ដានីៈ ចុះអ្នកនេសាទថៃ?

ផុនៈ អ្នកនេសាទថៃចាប់ គេមិនចាប់ទេ គេគ្រាន់តែបាញ់បន្លាចហ្នឹង ។

ដានីៈ ហើយបាញ់តម្រង់ហ្នឹង?

ផុនៈ បាញ់យកស្លាប់ហ្នឹង ។

ដានីៈ មានបាញ់ដែរ?

ផុនៈ	មាន ឲ្យតែចូលដែនទឹកយើង កំណត់១២គីឡូ បើគៀកព្រំដែនប្រទេសថៃហើយនឹងយើង ហ្នឹងអត់ទេ ហើយបើថាចូលជម្រៅដែនទឹកយើង១២គីឡូហើយគេចាប់ផ្ដើមឲ្យយើងទៅ ។

ដានី៖	ចុះពូខាងកងទ័ពយួនអីមានដែលចូលមកទេ ហើយមានដែលបាញ់ឬក៏ចាប់បានទេ?

ផុនៈ	កាលជំនាន់ហ្នឹងអត់មានទេ ។

ដានី៖	អ្នកនេសាទគេប្រាប់ថាឲ្យតែចូលមកដីយើងបាញ់ហ្មង យើងមិនបាច់ទៅចាប់ទៅអីមកទេ?

ផុនៈ	បាទ! កាលហ្នឹងគេអត់ឲ្យយកមនុស្សដាក់លើនាវាទឹកទេ ឧទាហរណ៍ឈ្លើយសឹក និយាយរួមទៅអ្នកណាក៏ដោយ សូម្បីតែទ័ពគ្នាឯងហ្នឹងគ្មានភារកិច្ចអីអញ្ចឹងយើងអត់ទៅលេងនាវាហ្នឹងបានទេ លុះត្រាតែយើងស្គាល់ជិតស្និទ្ធ ធ្លាប់នៅជាមួយគ្នា មានប្រធាននៅលើនាវាមួយគេស្គាល់គ្នាអញ្ចឹងហៅទៅលេង អាហ្នឹងទៅបាន តែបើអត់មានការងារអីទៅអត់បានទេ ។

ដានី៖	ចុះពូធ្លាប់មកប្រជុំជាមួយ តាមុត ប៉ុន្មានដងដែរ?

ផុនៈ	រាប់មិនឈ្នះទេរឿងប្រជុំ ។

ដានី៖	ហើយពេលប្រជុំហ្នឹងគាត់ច្រើនដាក់ផែនការយ៉ាងម៉េច?

ផុនៈ	កាលនោះវានយោបាយផ្សេង ហើយផែនការវាចេះតែមានហើយ ។

ដានី៖	អញ្ចឹងប្រជុំរាល់ខែ?

ផុនៈ	មិនទៀងទេ ជួនកាលគាត់មានបណ្ដាញគេធំៗ គេមកធ្វើការជាមួយគាត់ ហើយយើងតូចតាចហ្នឹងគេគ្រាន់តែបន្តប្រាប់យើងធ្វើអញ្ចេះធ្វើអញ្ចោះ ។

ដានី៖	ប៉ុន្តែដូចថាកាលពីដំបូងយើងប្រជុំរឿងទូទៅទាំងអស់គ្នា?

ផុនៈ	អាហ្នឹងដំបូងរឿងនយោបាយ រៀនទូទៅអញ្ចឹងហើយបានគេចំរាញ់រើសទៅកងជើងទឹក ហើយអ្នកដែលអត់មាននេះទេ មកជើងវិញធ្វើស្រែធ្វើអីជាមួយប្រជាជនទៅ ។

ដានី៖	ចុះដល់ពេលយើងទៅជើងទឹកហើយ យើងមកប្រជុំជាមួយ តាមុត ដែរ?

ផុនៈ	អត់ទេ មានផ្នែកៗគេ ។

ដានី៖	ប៉ុន្តែកាល តាមុត គាត់ទៅប្រជុំហ្នឹងពូមានធ្លាប់ឃើញគាត់ទៀតទេ?

ផុនៈ	អត់ទេ! គាត់តាមបណ្ដាញ ដល់ពេលអញ្ចឹងគាត់តាមបណ្ដាញរបស់គាត់ គេមេគ្រប់គ្រងធំ ឧទាហរណ៍ថា ទៅកោះកុងអញ្ចឹងមាននាវាប៉ុន្មាន ដូចថាមាន៣គ្រឿងអញ្ចឹងវាមានប្រធានរួម១ ។

ដានី៖	ពីណាគេប្រធានរួមនៅកោះកុង?

ផុនៈ	ប្រធានស្លាប់បាត់ហើយ ឈ្មោះ តាស៊ីម កាលជំនាន់៧៩គាត់នៅជើង ។

ដានី៖ នៅដើងហ្នឹងទៅណា នៅខាងអន្លង់វែង?

ផុន៖ អត់ទេ មិនមែននៅអន្លង់វែង នៅម៉ាជួរស៊ីសុផុននេះ ។

ដានី៖ អ៎! នៅខាងម៉ាឡៃវិញ?

ផុន៖ បាទ!

ដានី៖ ចុះពូនៅកោះកុងរហូតដល់រត់យួនហ្នង?

ផុន៖ បាទ!

ដានី៖ ហើយកាលឆ្នាំ៧៩ហ្នឹងពូរត់យ៉ាងម៉េច?

ផុន៖ កាល៧៩ខ្ញុំមិនមែនរត់ពីកោះកុងណា ខ្ញុំមកធ្វើនាវាវ៉ានៅដៃវៀម រត់ពីវៀមហ្នឹងមក ។

ដានី៖ រត់មកធ្វើនាវាវ៉ានៅដៃវៀម?

ផុន៖ បាទ!

ដានី៖ ហើយរត់យ៉ាងម៉េចទៅពូ?

ផុន៖ រត់ទៅឡើងចំលងគោជីផាតនោះ ។

ដានី៖ ទៅជីផាតវិញ?

ផុន៖ បាទ!

ដានី៖ ហើយយើងបើកនាវាវ៉ារត់ឬក៏យ៉ាងម៉េច?

ផុន៖ នាវាវ៉ាខ្ញុំទៅចោលនៅដៃតាផាតនោះ ។

ដានី៖ ហើយគ្នាច្រើនទេ?

ផុន៖ គ្នាច្រើនណាស់ ច្របូកច្របល់ណាស់កាលហ្នឹង ។

ដានី៖ ហើយកាលហ្នឹងប្រធានខាងកងពលបញ្ជាឲ្យយើងបើកទៅហ្នឹងឬមួយក៏យើងបើកទៅខ្លួនឯង?

ផុន៖ អត់ទេ ដាច់ប្រព័ន្ធបញ្ជាទាំងអស់ គ្មានអ្នកណាបញ្ជាទេ ទៅខ្លួនឯងហ្នង ។

ដានី៖ យើងចេះតែរុញទៅខ្លួនឯងហ្នង?

ផុន៖ គេបញ្ជារថាឲ្យដឹកគ្រួសារទ័ពចេញពីកំពង់សោមហ្នឹង ដឹកអាដៃស្ទឹងហាវដែលគាត់នេះជាមួយខ្ញុំពីដើមហ្នឹង ហ្នឹងទៅអាដៃហ្នឹង អាដៃស្ទឹងហាវហ្នឹង ។

ដានី៖ ពូដឹកពួកទ័ពទៅ?

ផុន៖ ហ្នឹងហើយ ជញ្ជូនទៅ ដឹកពីហ្នឹងទៅដាក់នៅចំលងគោ ។

ដានី៖ ចំលងគោខាងជីផាតហ្នឹង?

ផុន៖ បាទ!

ដានីៈ ដឹកទៅប៉ុន្មានជើង?

ភុនៈ ខ្ញុំអត់បានដឹកផងពួកខ្ញុំ ដឹកតែពួកគេអាកប៉ាល់ ពួកអាកប៉ាល់ឈើ ពួកអា៨០០សេសហ្នឹង គេបានដឹក តែខ្ញុំអត់បានដឹកផង អាហ្នឹងតូចមួយហ្នឹង ប៉េស៊ីអេសតូចមួយហ្នឹង ដឹកមនុស្ស បានប៉ុន្មានណាស់ គ្រាន់តែនៅការពារគេហ្នឹង ។

ដានីៈ អាប៉េស៊ីអេសហ្នឹងលឿនមែន?

ភុនៈ លឿនគួរសមដែរហ្នឹង បើទូកឈើ.... ។

ដានីៈ រត់អត់ទាន់ទេ?

ភុនៈ បើទូកឈើរត់អត់ទាន់វាទេ ទូកឈើកំណត់តែចូលក្នុងរ៉ដាវាហើយ ១៥នាទីដាប់ហើយ ។

ដានីៈ ចុះពូមកដល់ខាងចំលងគោជីផាតហ្នឹងហើយយ៉ាងម៉េចទៀត ចោលកប៉ាល់ហ្នឹងហើយយើង ទៅណាមកណាទៀត?

ភុនៈ មកនៅទ័ពថ្មីរជើងដដែលហ្នឹង ។

ដានីៈ មកនៅទ័ពថ្មីរជើងនៅណាទៅ?

ភុនៈ នៅហ្នឹង នៅម៉ាដូរតាផាត នៅហ្នឹងបានខ្វីទេបើគិតទៅ ។

ដានីៈ មកនៅជាមួយពីណាវិញ?

ភុនៈ នៅហ្នឹង ទេកាលហ្នឹងរកមេរកអីគ្រប់គ្រងច្បាស់លាស់មិនឃើញទេកាលហ្នឹង អង្គភាពប្រឡូក ប្រឡល់ មិនដឹងណាណីទេ តែធ្លាប់នៅជាមួយគ្នាពីមុនអញ្ចឹងធ្លាប់គេធ្វើមេយើងពីមុនជួបគ្នា ក៏នៅជាមួយគ្នាទៅ និយាយអាណាត់អាណែងហ្នឹងកាលហ្នឹង អាខ្លះមិនដឹងអង្គភាពនៅណា ហើយមេគ្រប់គ្រងនៅណា ប្រឡូកប្រឡល់ប្រជាជនផងទ័ពផងណា៎ ។

ដានីៈ ដល់ពេលចេញពីហ្នឹងមកនៅណាទៀត?

ភុនៈ ចេញពីហ្នឹងមកនៅថៃ ។

ដានីៈ គេកៀរយើងមកនៅជំរុំ?

ភុនៈ ទៅនៅជំរុំ ទេមិនមែនទេ ទៅនៅជើងទេ កាលហ្នឹងមិនទាន់នៅជំរុំទេ កាលហ្នឹងធ្លាក់មកថៃ ហើយឆ្លងស្ទឹងមេទឹក ហើយទៅឡែម ហើយកាលហ្នឹងថៃគេដុតកាំភ្លើងផ្សេង ហើយឡាន ដឹកមនុស្សផ្សេង មួយយប់ដីគេហ្នឹង ហើយចេញមកឡែមហ្នឹងទៅ ទៅដល់ឡែមហ្នឹងប្រឡូក ប្រឡល់ណាស់មិនដឹងស្អីៗទេ ទ័ពគេអត់ឲ្យចូលជំរុំភៀសខ្លួនទេណា៎ គេឲ្យចេញមកវិញ ព្រំដែនមកដីថៃហើយនឹងយើងណា៎ នៅតាមខ្សែព្រំដែនហ្នឹង នៅហ្នឹងហើយបានវិលមក សំឡូត ។

ដានីៈ ឆ្នាំណាបានពូវិលមកសំឡូត?

ភុនៈ យូដែរហ្នឹង ។

ដានីៈ ហើយពូរៀបការឆ្នាំណា?

ភុនៈ ៩២ នេះហ្នឹង ។

ដានីៈ អញ្ចឹងទើបតែរៀបការឆ្នាំ៩២នេះទេ?

ភុនៈ បាទ!

ដានីៈ ហើយជួបមីងនៅណា នៅសំឡូត?

ភុនៈ ជួននៅសំឡូតហើយបានចេញទៅជំរុំ ។

ដានីៈ ជំរុំណា?

ភុនៈ ជំរុំសាយធូហ្នឹង អាចុងក្រោយហ្នឹង ។

ដានីៈ ចុះពូពិការភ្នែកហ្នឹង ពិការឆ្នាំណាទៅ?

ភុនៈ ឆ្នាំ៨៦ ។

ដានីៈ ពេលហ្នឹងយើងយ៉ាងម៉េចបានយើងពិការភ្នែក?

ភុនៈ ត្រូវមីន ។

ដានីៈ ត្រូវមីនខាងយួនឬក៏ខាងណា?

ភុនៈ មីនយួន ។

ដានីៈ អាហ្នឹងពេលដែលយើងកំពុងតែវ៉ៃគ្នាឬក៏យ៉ាងម៉េច?

ភុនៈ អត់វ៉ៃទេ មីនគេដាក់ ។

ដានីៈ កាលហ្នឹងគេដាក់នៅណា?

ភុនៈ គេហៅភ្នំ៣០០ គេហៅក្បាលអូតាទៀក ។

ដានីៈ ភ្នំ៣០០ហ្នឹងនៅខាងណា នៅខាងសំឡូតមែន?

ភុនៈ ខាងសំឡូត ។

ដានីៈ ហើយភ្នំ៤០០ខាងច្រកព្រំដែន?

ភុនៈ បាទ! ភ្នំ៤០០ ហើយ៤៥៣នៅជាប់ហ្នឹងដែរ ហើយ៣០០នៅណានោះ ។

ដានីៈ អញ្ចឹងពូនៅសំឡូតនៅជាមួយ តាម៉េត ទៀតទៅ?

ភុនៈ អត់ទេ នៅសំឡូតលែងនៅជាមួយ តាមុត តាមុត ទៅកាន់កងពលនៅកោះកុង នៅតែ តាម៉េត ទេ តាម៉េត គាត់គ្រប់គ្រងនៅសំឡូត មេកងជើងអាកាសហ្នឹង ដល់ពេលគាត់គ្រប់គ្រងធំនៅហ្នឹង ហើយ តាមុត គាត់ទៅកាន់កងពលនៅកោះកុង កាលហ្នឹងគេចែកកងពលគ្នា ។

ដានី: ដល់ពេលឆ្នាំ៩៦ពូមកនេះទៀត?

ផុន: បាទ?

ដានី: ឆ្នាំណាដែលពូមកនៅនេះ?

ផុន: នៅនេះទាល់តែត្រូវគេត្រូវគ្នាចុងក្រោយនេះហើយហ្នឹង ចុងក្រោយគ្នាណា៎ មិនមែនត្រូវគ្នាម៉ាឈុលដំបូង១០ខែហើយផ្ទុះខ្មែរក្រហមៗគ្នាទៀតទេណា៎ ខ្ញុំមកនៅនេះដល់ពេលចុងក្រោយបញ្ចប់ហើយណា៎ មានជំរុំណាឡើងក្រោយទៀត មានតែជំរុំហ្នឹងហើយក្រោយគេឡើងមកត្រូវគ្នាស្រួលបួលរហូត ។

ដានី: ហើយពូម៉េចបានជាផ្លាស់ពីសំឡូតមកនៅវាលវែងនេះ?

ផុន: ខ្ចិលទៅនោះមកនេះហ្នឹងទៅ កាលហ្នឹងគេគួស័គ្រចិត្តតើ បើយើងចង់ទៅសំឡូតគេដឹកទៅសំឡូត ចង់មកនៅវាលវែងគេដឹកមកនៅវាលវែង អញ្ចឹងខ្ញុំអត់ទៅសំឡូតទេខ្ញុំមកនៅនេះ ។

ដានី: អញ្ចឹងដំបូងពូនៅសំឡូត?

ផុន: បាទ!

ដានី: ដល់ពេលពូទៅសំឡូតហើយពូទៅជំរុំ?

ផុន: ហ្នឹងហើយ ។

ដានី: ហើយម៉េចបានជាចេញពីសំឡូតមកនៅជំរុំ?

ផុន: ចុះកាលហ្នឹងមិនរ៉ៃគ្នា ហើយយើងមិនភៀសទៅជំរុំ អស់ដីគេនៅទ័ពៗ ហើយយើងចេះតែភៀសធ្លាក់ទៅជំរុំទៅ គ្រួសារទ័ពគ្រួសារអីហ្នឹងធ្លាក់ខ្លួនទៅជំរុំទាំងអស់គ្នាទៅ នៅសល់តែកម្លាំងវ៉ៃតាមព្រំដែន ហើយទ័ពខ្លះក៏ឡើងទៅជំរុំដែរ គ្រាន់តែចេញពីជំរុំមកវ៉ៃវិញហ្នឹង ។

ដានី: អញ្ចឹងពូអត់ចាំឆ្នាំទេ ពេលដែលពូមកវាលវែងហ្នឹង?

ផុន: ឆ្នាំ៩៦មកហ្នឹង ។

ដានី: ពូមកហ្នឹងមកនៅហ្នឹងហ្នង?

ផុន: បាទ!

ដានី: ហើយនៅចំហ្នឹងហ្នង?

ផុន: បាទ! មកតាំងពីផ្លូវនេះអត់ទាន់កើតផង ផ្លូវនេះសុទ្ធតែមីនណែនហ្នឹងអត់មានផ្លូវដើរផង ។

ដានី: អញ្ចឹង?

ផុន: បាទ!

ដានី: ហើយផ្លូវនេះយើងធ្វើខ្លួនឯងមែន?

ផុន: អត់ទេ វិស្វកម្មគេធ្វើ ។

ដានីៈ វិស្សុកម្មធ្វើ?

ឆុនៈ បាទ! មុនដំបូងគេឲ្យប្រជាជនធ្វើយកកម្លាំងពលកម្ម យើងធ្វើកម្លាំងចប ហើយដំបូងខ្មែរក្រហមចាស់ៗហ្នឹងគេរៀបចំថារាវមិនរាវអីតាំងពីទួលគ្រោះ គេឲ្យអន្តរណ៍ អាហ្នឹងទ័ពខ្មែរក្រហមចាស់ហ្នឹងគេរាវ ដល់ពេលក្រោយមកបានកងវិស្សុកម្មគេធ្វើ វេទនាចង់ងាប់ ។

ដានីៈ ដំបូងវេទនា?

ឆុនៈ បាទ!

ដានីៈ តែឥលូវលែងហើយ?

ឆុនៈ តែគ្មានអ្នកណាមានលុយមានកាក់ទេ ។

ដានីៈ តែឥលូវលែងអីហើយ?

ឆុនៈ ឥលូវមានអីទៀត ។

ដានីៈ ហើយចុះពូធ្លាប់ទៅលេងផ្ទះទេនៅកំពត?

ឆុនៈ ទៅញឹកដែរហ្នឹង ។

ដានីៈ ទៅលើកទី១ឆ្នាំណា?

ឆុនៈ មិនដឹងឆ្នាំណាទេ ។

ដានីៈ ចុះមីងអ្នកស្រុកកំនើតនៅជាមួយគ្នាដែរ?

ឆុនៈ នៅជាមួយគ្នា ។

ដានីៈ ឆ្នាំដំបូង?

ឆុនៈ មិនដឹងទេ កាលនៅសំឡូតខ្ញុំទៅដែរ កាលត្រូវគ្នាដំបូងហ្នឹង ខ្ញុំទៅហើយដល់ពេលមកពីស្រុកវិញ គេវ៉ៃគ្នាមួយសារទៀត តែខ្ញុំឈប់ធ្វើទាហានយូហើយតាំងពីជំនាន់នោះមក ព្រោះខ្ជិលតាំងពីត្រូវគ្នាមួយផង គេវ៉ៃគ្នាលើកក្រោយគ្មានវ៉ៃគ្នាអីទេ ខ្ញុំឈប់ហើយ ហើយម្យ៉ាងឈប់គេអត់ទំនាស់អីទេ ព្រោះយើងពិការ ។

ដានីៈ ចុះពូកាលនៅសំឡូតកាលហ្នឹងយើងល្បីរឿងបរឡាងត្បូងច្រើន ពូធ្លាប់បានទៅជីកត្បូងជីកអីនឹងគេដែរទេ?

ឆុនៈ ជីកអី គេអត់ជីកផង គេឲ្យថៃជីក ហើយខ្មែរយើងចេះតែលួចជីកអញ្ចឹងទៅ បានអីបើគេមិនឲ្យធ្វើ ។

ដានីៈ ចុះយើងធ្វើកងទ័ពជាមួយគ្នា?

ឆុនៈ គេអត់ឲ្យធ្វើជាមួយគ្នាទេ ។

ដានីៈ ចុះគេបានលុយមកគេចែកយើងទេ?

ឆុនៈ	គេមិនចែកយើងទេ គេសម្រាប់គ្រប់គ្រងទ័ព ។

ដានីៈ	យើងគ្រប់គ្រងទ័ព បានន័យថាយើងយកលុយមកយកមកចែកឲ្យកងទ័ព?

ឆុនៈ	អត់ទេ គេអត់ចែកលុយទេ គេចែកទិញអង្ករទិញម្ហូបអាហារបើកឲ្យយើងអញ្ចឹងណា៎ គេមិនមែនឲ្យជាលុយជាកាក់អីទេ គេមានមេគេគ្រប់គ្រងផ្សេង ក្រុមហ៊ុនរកស៊ីជាមួយថៃ ។

ដានីៈ	ពីណាគេអ្នកគ្រប់គ្រងនៅត្បូងហ្នឹង?

ឆុនៈ	តាទិត ។

ដានីៈ	គាត់អ្នកគ្រប់គ្រងអ្នករកស៊ីជាមួយថៃ ហើយយកលុយហ្នឹងមកចែកឲ្យ?

ឆុនៈ	យកលុយហ្នឹងមកទិញអង្ករទិញម្ហូបអីសម្រាប់ជួយគ្រួសារទ័ពហ្នឹងណា៎ ។

ដានីៈ	ហើយគ្រួសារគាត់មានទេ គ្រួសារ តាទិត?

ឆុនៈ	មាន តែគេអ្នកកាន់ហើយមិនដែលអត់លុយទេ គេអ្នកកាន់លុយកាន់ត្បូងហើយ ។

ដានីៈ	គាត់អ្នកកាន់លុយកាន់ត្បូងហើយ?

ឆុនៈ	បាទ!

ដានីៈ	អញ្ចឹងម៉េចក៏គាត់នៅសល់លុយដែរ?

ឆុនៈ	អ្នកកាន់ហើយមិនសល់ម៉េច ។

ដានីៈ	ខ្ញុំដូចជាអស់សំនួរអីសួរពូទៀតហើយ តើពូមានអ៊ីចង់បន្ថែមនៅអ៊ីដែលខ្ញុំមិនទាន់បានសួរនាំពូទេ?

ឆុនៈ	អត់មានអីបន្ថែមទេ ។

ដានីៈ	អញ្ចឹងខ្ញុំអរគុណពូច្រើនដែលបានអនុញ្ញាតិឲ្យខ្ញុំសួរនាំពូទាក់ទងនឹងរឿងរ៉ាវរបស់ពូ ។

ឆុនៈ	បាទ!